**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៤៨៩ ព.ណ.ន.ន.

ថ្ងៃ ច័ន្ទ ១៤ កើត ខែ ទុតិយាសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០២៣

## សេចក្តីជូនដំណឹង

យោងរបាយការណ៍លទ្ធផលកិច្ចប្រជុំលើកទី៤២ នៃគណៈកម្មាធិការសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ កាលពីថ្ងៃទី១៩ ដល់២២ ខែមិថុនា ឆ្នាំ២០២៣ នៅទីក្រុងហ្សាកាតា ប្រទេសឥណ្ឌូនេស៊ី រដ្ឋជាសមាជិកអាស៊ានទាំងអស់ ក្នុងនោះរួមមានប្រទេសកម្ពុជាផងដែរ ត្រូវអនុវត្តឱ្យបានពេញលេញនៃការចេញនិងប្រើវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី ជាទម្រង់អេឡិចត្រូនិច (e-Form D) ត្រឹមខែមករា ឆ្នាំ២០២៤។ ក្នុងន័យនេះ ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន **អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា** ដែលជាផលិតករ និងអ្នកនាំចេញទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងពាណិជ្ជកម្ម នឹងបញ្ឈប់ការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី ជាទម្រង់ក្រដាស (CO Form D Hard Copy) **នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ តទៅ** ហើយរាល់ការស្នើសុំ វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី (CO Form D) តាមប្រព័ន្ធស្វ័យប្រវត្តកម្មជាមួយគេហទំព័រ https://co.moc.gov.kh/ សម្រាប់ការស្នើសុំនាំចេញទំនិញទៅកាន់ទីផ្សារអាស៊ាន ក្រសួងពាណិជ្ជកម្ម នឹងចេញជូនតែវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី ជាទម្រង់អេឡិចត្រូនិក (e-Form D) តែប៉ុណ្ណោះ។

ចំពោះព័ត៌មានលម្អិត សូមទំនាក់ទំនងមន្ត្រី នៃនាយកដ្ឋាននាំចេញ-នាំចូល ដូចមានរាយនាមខាងក្រោម៖

១. លោក ស៊ី បាទិត្យ — អនុប្រធាននាយកដ្ឋាននាំចេញ-នាំចូល
ទូរស័ព្ទលេខ៖ ០១២ ៩៤៨ ៤៨៤ — សារអេឡិចត្រូនិច៖ batithsy@yahoo.com

២. លោក ស្វាយ សុផល — ប្រធានការិយាល័យ នៃនាយកដ្ឋាននាំចេញ-នាំចូល
ទូរស័ព្ទលេខ៖ ០១១ ៧៥៧ ១៦៥ — សារអេឡិចត្រូនិច៖ sophal.svay@yahoo.com

៣. លោក សុខ វណ្ណថុល — អនុប្រធានការិយាល័យ នៃនាយកដ្ឋាននាំចេញ-នាំចូល
ទូរស័ព្ទលេខ៖ ០១២ ៥៩៥ ៦១៦ — សារអេឡិចត្រូនិច៖ vanthol@gmail.com

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាងកញ្ញា** ជាផលិតករ និងអ្នកនាំចេញទាំងអស់មេត្តាជ្រាប និងសហការអនុវត្តឱ្យមានប្រសិទ្ធភាព។

**សូមអរគុណ!**

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469